ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១១០...អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការកែសម្រួលព្រំតំបន់៣ នៃតំបន់បឹងទន្លេសាប ក្នុងភូមិសាស្ត្រឃុំព្រៃកប្បាស ឃុំព្រៃកនិទ្ទ និងឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ស្ដីពីការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧ ៤០៦ ហិកតា ស្ថិតក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

កែសម្រួលព្រំតំបន់៣ នៃបឹងទន្លេសាប ស្ថិតក្នុងភូមិសាស្ត្រឃុំព្រែកហ្លួង ឃុំព្រែកនរិន្ទ និងឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដែលកំណត់ដោយអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដើម្បីផ្ដល់ជូនប្រជាពលរដ្ឋចំនួន ១៩១ គ្រួសារ បានបន្តប្រើប្រាស់ និងអាស្រ័យផល ក្នុងនោះ ៖

១.ឃុំព្រែកហ្លួង ដីទំហំ ១៨២ហិកតា ៣១អា ជូនប្រជាពលរដ្ឋចំនួន ១២៤គ្រួសារ។

២.ឃុំព្រែកនរិន្ទ ដីទំហំ ១៥២ហិកតា ៦៤អា ជូនប្រជាពលរដ្ឋចំនួន ៥៨គ្រួសារ។

៣.ឃុំពាមឯក ដីទំហំ ៦៧ ហិកតា ៤៥ អា ជូនប្រជាពលរដ្ឋចំនួន ៩គ្រួសារ។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរទន្លេសាប និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែមីនា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីបង្ហាញទីតាំងព្រំតំបន់៣ នៃដែនព្រៃលិចទឹកបឹងទន្លេសាបក្នុងភូមិសាស្ត្រ ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដែលស្នើសុំកែសម្រួល




| Name | ID | E | N |
|---|---|---|---|
| 276 | 58 | 308494 | 1465135 |
| 275 | 57 | 309132 | 1465287 |
| 273 | 54 | 310447 | 1465014 |
| 272 | 52 | 311422 | 1464910 |
| 270 | 48 | 312100 | 1464619 |
| 286 | 50 | 312621 | 1464162 |
| 262 | 59 | 315515 | 1464738 |
| 277 | 60 | 308249 | 1465135 |
| 278 | 62 | 308001 | 1464991 |
| 279 | 63 | 307534 | 1464697 |
| 281 | 64 | 306988 | 1464791 |
| 282 | 65 | 306436 | 1465227 |
| 283 | 66 | 306954 | 1465878 |
| 284 | 67 | 306580 | 1465962 |
| 289 | 74 | 306118 | 1467676 |
| 290 | 76 | 306021 | 1467948 |
| 286 | 69 | 306287 | 1466747 |
| 255 | 40 | 320227 | 1461095 |
| 257 | 43 | 319069 | 1460734 |
| 254 | 44 | 320794 | 1460560 |
| 256 | 45 | 319446 | 1460867 |
| 259 | 46 | 318211 | 1461737 |
| 260 | 53 | 318705 | 1462713 |
| 261 | 56 | 318659 | 1463782 |
| 266 | 51 | 312939 | 1462710 |
| 265 | 55 | 313973 | 1463447 |
| 267 | 47 | 312645 | 1461957 |